ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# អាជ្ញាធរទន្លេសាប

# ផែនការសកម្មភាពការងារប្រចាំឆ្នាំ ២០១៨

# អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប

រៀបចំដោយ ៖ អាជ្ញាធរទន្លេសាប

សម្របសម្រួលក្នុងការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍន៍តំបន់ទន្លេសាប

ខែមករា ឆ្នាំ ២០១៨

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរទន្លេសាប

លេខ :...០១៨.......អទស

ថ្ងៃ ពុធ ៨ កើត ខែ មាឃ ឆ្នាំ រកា ព.ស. ២៥៦១

រាជធានីភ្នំពេញ, ថ្ងៃទី ២៤ ខែ មករា គ.ស. ២០១៨

**ជម្រាបមក**

**ឯកឧត្តម លោកប្រធាន និងអនុប្រធានក្ដាប់រួមនាយកដ្ឋាន**

**ក្រោមឱវាទអគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប**

**កម្មវត្ថុ ៖** ការដាក់ឲ្យអនុវត្តន៍ផែនការសកម្មភាពការងារប្រចាំឆ្នាំ 2018 របស់អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប ។

**ជូនភ្ជាប់៖** ផែនការសកម្មភាពការងារប្រចាំឆ្នាំ 2018 របស់អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប ។

ន័យដូចមានចែងក្នុងកម្មវត្ថុ និងជូនភ្ជាប់ខាងលើ ខ្ញុំសូមជម្រាបជូនឯកឧត្តម លោកប្រធាន និងអនុប្រធានក្ដាប់រួម ជ្រាបថា ៖ ក្នុងស្មារតីយកចិត្តទុកដាក់ជម្រុញនូវកិច្ចការការពារធនធានធម្មជាតិ និងជីវៈចម្រុះ ដែលជាផ្នែកមួយយ៉ាងសំខាន់ក្នុងការលើកកម្ពស់សេដ្ឋកិច្ចជាតិ និងការទ្រទ្រង់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋនៅតំបន់បឹងទន្លេសាប និងតំបន់ពាក់ព័ន្ធ ប្រកបដោយចិរភាព ។

អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប បានរៀបចំផែនការសកម្មភាពការងារប្រចាំឆ្នាំ 2018 ដើម្បីជម្រុញប្រសិទ្ធភាពការអនុវត្តផែនការយុទ្ធសាស្ត្រ អាជ្ញាធរទន្លេសាប 2016-2020 ឲ្យទទួលបានជោគជ័យ និងបន្តពង្រឹងការអនុវត្តបេសកកម្មស្នូលរបស់អាជ្ញាធរទន្លេសាប ក្នុងការសិក្សាស្រាវជ្រាវ តាមដានត្រួតពិនិត្យ និងវាយតម្លៃ អំពីសក្ដានុពលសេដ្ឋកិច្ច សង្គមកិច្ច និងធនធានធម្មជាតិ ស្របតាមអាណត្តិការងារសម្របសម្រួលដល់ការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍន៍តំបន់ទន្លេសាប ប្រកបដោយនិរន្តរភាព ។

អាស្រ័យហេតុនេះ សូមឯកឧត្តម លោកប្រធាន និងអនុប្រធានក្ដាប់រួមនាយកដ្ឋាន ក្រោមឱវាទអគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប អនុវត្តន៍ឲ្យបានល្អប្រសើរ និងមានប្រសិទ្ធភាព ។

**រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម**

**និងជា ប្រធានអាជ្ញាធរទន្លេសាប**

**លឹម គានហោ**

អគារលេខ: ៣៦៤,មហាវិថី ព្រះមុនីវង្ស,សង្កាត់ ផ្សារដើមថ្កូវ,ខណ្ឌ ចំការមន,រាជធានីភ្នំពេញ, ទូរស័ព្ទ / ទូរសារលេខ: (៨៥៥) ២៣ ៧២៧ ៤៥៤
# 364 Monivong Blvd., Phsar Deumthkov, Khan Chamkarmorn, Phnom Penh, Cambodia. Phone/Fax: (855) 23 727 454, Website: www. tonlesap.gov.kh

# អារម្ភកថា

បឹងទន្លេសាប គឺជាបឹងទឹកសាបធំជាងគេបំផុតក្នុងភូមិភាគអាស៊ីអាគ្នេយ៍ និងជាបេះដូងនៃប្រទេសកម្ពុជា មានតម្លៃមិនអាចកាត់ថ្លៃបាន ។ ទន្លេសាប និងបឹងទន្លេសាប គឺជាប្រព័ន្ធផ្លូវទឹកទំនាក់ទំនងយ៉ាងសំខាន់បំផុត ដែលទទួលរងនូវឥទ្ធិពលរបបទឹកពីទន្លេមេគង្គ ។ បឹងទន្លេសាប ស្រូបយកទឹកពីទន្លេមេគង្គនៅរដូវវស្សា និងបញ្ចេញទឹកទៅទន្លេមេគង្គវិញនៅរដូវប្រាំង បង្កើតបានជាបាតុភូតជលសាស្ត្រធម្មជាតិមួយកម្រមាននៅលើពិភពលោក និងបាននាំមកនូវដីល្បាប់ដ៏មានជីជាតិ ចាក់បំពេញវាលទំនាបលិចទឹកនៃតំបន់ព្រៃលិចទឹកដ៏ធំល្វឹងល្វើយ ដែលជាជម្រក និងបង្កបានជាចំណី សម្រាប់ជីវៈចម្រុះយ៉ាងសម្បូរបែបមានពពួកមច្ឆាជាតិ បក្សី ល្មូន ថនិកសត្វ និងរុក្ខជាតិគ្រប់ប្រភេទ ។ ក្រៅពីតួនាទីជាបឹង ទទួលយកទឹក និងជួយកាត់បន្ថយគ្រោះទឹកជំនន់ពីទន្លេមេគង្គ វាក៏ជាប្រភពសន្តិសុខស្បៀង ជួយទ្រទ្រង់ដល់ជីវភាពរស់នៅរបស់ប្រជាជនកម្ពុជា និងជួយទ្រទ្រង់ដល់វិស័យសេដ្ឋកិច្ច សង្គម វប្បធម៌ និងបរិស្ថានប្រទេសជាតិទាំងមូល ។

បច្ចុប្បន្នសម្ពាធនៃការអភិវឌ្ឍ និងកំណើនប្រជាពលរដ្ឋ បានធ្វើឲ្យហានិភ័យនៃបឹងទន្លេសាប បាននឹងកំពុងទទួលរងនូវការគម្រាមកំហែងយ៉ាងធ្ងន់ធ្ងរ មកដល់សុខមាលភាពបឹង បរិស្ថាន ជីវៈចម្រុះ និងធនធានធម្មជាតិ ដូចជា ៖ ការប្រើប្រាស់បច្ចេកវិជ្ជាខុសបទដ្ឋានបច្ចេកទេស ការកាប់បំផ្លាញ រុករានទន្រ្ទានយកដីព្រៃលិចទឹក ការធ្វើអាជីវកម្មហួសកម្រិតលើធនធានជលផល បម្រែបម្រួលអាកាសធាតុ ការសាងសង់ហេដ្ឋារចនាសម្ព័ន្ធ និងការសាងសង់ទំនប់វារីអគ្គិសនីនៅផ្នែកខាងលើ ជាដើម ។

ដោយមើលឃើញពីសារៈសំខាន់នៃបឹងទន្លេសាប និងដើម្បីចូលរួមចំណែកក្នុងកិច្ចការការពារធនធានធម្មជាតិ និងជីវៈចម្រុះ ដែលជាផ្នែកមួយយ៉ាងសំខាន់ក្នុងការលើកកម្ពស់សេដ្ឋកិច្ចជាតិ និងការទ្រទ្រង់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ជាពិសេសការធានាដល់ការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍន៍ធនធានដ៏កម្រនៅតំបន់បឹងទន្លេសាប និងតំបន់ពាក់ព័ន្ធប្រកបដោយនិរន្តរភាព ក៏ដូចជាការចូលរួមពង្រឹងប្រសិទ្ធភាពគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា **អាជ្ញាធរទន្លេសាប** បានរៀបចំផែនការសកម្មភាពការងារប្រចាំឆ្នាំ 2018 ដែលជាផែនការសកម្មភាពនៃឆ្នាំទី 5 របស់អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប បន្តពីការអនុវត្តផែនការសកម្មភាពការងារប្រចាំឆ្នាំ 2017 ។

ផែនការសកម្មភាពការងារប្រចាំឆ្នាំ 2018 គឺជាសកម្មភាពការងារលម្អិត ក្នុងការប្រតិបត្តិអនុវត្តន៍ការងារប្រចាំឆ្នាំរបស់អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប រួមជាមួយការចូលរួមសហការពីបណ្ដាក្រសួង ស្ថាប័នទាំងកម្រិតថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ សង្គមស៊ីវិល អង្គការជាតិ-អន្តជាតិ និងដៃគូអភិវឌ្ឍន៍នានា ដើម្បីជម្រុញ ប្រសិទ្ធភាពនៃការអនុវត្តផែនការយុទ្ធសាស្ត្រ អាជ្ញាធរទន្លេសាប 2016-2020 ឲ្យទទួលបានជោគជ័យ ។ ជាមួយខ្លឹមសារផែនការសកម្មភាពការងារនេះ ក៏ត្រូវបានរៀបចំបន្ស៊ីជាមួយគម្រោងសកម្មភាពការងារអាទិភាពសំខាន់ៗនៅក្នុងផែនការយុទ្ធសាស្ត្រ អាជ្ញាធរទន្លេសាប 2016-2020 ។ ជាពិសេស ស្របតាមតួនាទី ភារកិច្ចការងារ ដែលបានកំណត់ក្នុងអនុក្រឹត្យ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប ដើម្បីពង្រឹងប្រសិទ្ធភាពការងារ និងគាំទ្រដល់បេសកកម្ម

ការងាររបស់អាជ្ញាធរទន្លេសាបក្នុងការសម្របសម្រួលដល់ការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍន៍តំបន់ទន្លេសាប ប្រកបដោយនិរន្តរភាព ។

ផែនការសកម្មភាពការងារនេះ ចែកជា 4 ផ្នែកសំខាន់ៗគឺ ៖ ផ្នែកទី 1 រចនាសម្ព័ន្ធ និងតួនាទីភារកិច្ចរបស់អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប ។ ផ្នែកទី 2 វឌ្ឍនភាពការងារនៃផែនការសកម្មភាពប្រចាំឆ្នាំ 2017 បង្ហាញពីលទ្ធផលសម្រេចបាន និងបទពិសោធន៍នៃការអនុវត្តសកម្មភាពការងារនៅក្នុងឆ្នាំ 2017 ។ ផ្នែកទី 3 ផែនការសកម្មភាពការងារប្រចាំឆ្នាំ 2018 របស់អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប ដែលជាសកម្មភាពការងារលម្អិតប្រចាំឆ្នាំ និងផ្នែកទី 4 ឧបសម្ព័ន្ធ ។

ជាក់ស្តែង ផែនការសកម្មភាពការងារប្រចាំឆ្នាំ 2018 នេះ នឹងប្រើប្រាស់ធ្វើជាឧបករណ៍ជួយតម្រង់ទិសការងារដល់នាយកដ្ឋាន និងការិយាល័យស្ថិតក្រោមឱវាទអគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប សម្រាប់យកទៅអនុវត្តអោយមានប្រសិទ្ធភាព ហើយក៏ជាទស្សនទានដ៏សំខាន់មួយ សម្រាប់ផ្តល់ជូនដល់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងការគិតគូរពិចារណាធ្វើការវិភាជន៍ថវិកាប្រចាំឆ្នាំ និងដៃគូអភិវឌ្ឍន៍នានា ដែលមានគោលបំណងចូលរួមសហការ និងគាំទ្រទាំងផ្នែកថវិកា និងបច្ចេកទេស ដល់ដំណើរការការងាររបស់អាជ្ញាធរទន្លេសាប ។

# មាតិកា

**ទំព័រ**


**ផ្នែកទី ១ ៖** រចនាសម្ព័ន្ធ និងតួនាទីភារកិច្ចរបស់អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប ..... ១

១. លក្ខណៈទូទៅ ..... ១

២. រចនាសម្ព័ន្ធ និងការគ្រប់គ្រង ..... ២

**ផ្នែកទី ២ ៖** វឌ្ឍនភាពអនុវត្តផែនការសកម្មភាពប្រចាំឆ្នាំ 2017 ..... ៣

១. សេចក្តីផ្តើម ..... ៣

២. វឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាពឆ្នាំ 2017 ..... ៣

២.១. លទ្ធផលសម្រេចបានសំខាន់ៗ ..... ៣

២.២ លទ្ធផលរួមគាំទ្រការអនុវត្តផែនការយុទ្ធសាស្រ្ត ៥ ឆ្នាំ (២០១៦-២០២០) ..... ៥

៣. មេរៀន និងបទពិសោធន៍ការអនុវត្តផែនការសកម្មភាពប្រចាំឆ្នាំ 2017 ..... ៦

**ផ្នែកទី ៣ ៖** ផែនការសកម្មភាពប្រចាំឆ្នាំ 2018 របស់អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប ..... ៨

១. លក្ខណៈទូទៅ ..... ៨

២. សកម្មភាពការងារប្រចាំឆ្នាំ 2018 របស់អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប ..... ៨

៣. ម៉ាទ្រិចផែនការសកម្មភាព ឆ្នាំ ២០១៨ របស់ អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប ..... ១៥

**ផ្នែកទី ៤ ៖** ឧបសម្ព័ន្ធ ..... ៥៨

ឧបសម្ព័ន្ធ ១ តារាងម៉ាទ្រីចផែនការយុទ្ធសាស្រ្ត (2016-2020) របស់អាជ្ញាធរទន្លេសាប ..... ៥៨

ឧបសម្ព័ន្ធ ២ តារាងសង្ខេបការប៉ាន់ស្មានថវិកា ..... ៦១

ឧបសម្ព័ន្ធ ៣ អង្គការលេខរបស់អាជ្ញាធរទន្លេសាប ..... ៦២

ឧបសម្ព័ន្ធ ៤ ព្រះរាជក្រឹត្យ ស្តីពីការបង្កើតអាជ្ញាធរទន្លេសាប ..... ៦៣

ឧបសម្ព័ន្ធ ៥ ព្រះរាជក្រឹត្យ ស្តីពីការកែសម្រួលមាត្រាមួយចំនួនក្នុងការបង្កើតអាជ្ញាធរទន្លេសាប ..... ៧០

ឧបសម្ព័ន្ធ ៦ អនុក្រឹត្យ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន អាជ្ញាធរទន្លេសាប ..... ៧៥

ឧបសម្ព័ន្ធ ៧ ប្រកាស ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ការិយាល័យ ..... ៨០

# ផ្នែកទី ១

# រចនាសម្ព័ន្ធ និងតួនាទីភារកិច្ចរបស់អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប

## ១. លក្ខណៈទូទៅ

**អាជ្ញាធរទន្លេសាប** គឺជាស្ថាប័នថ្មីមួយ និងជាសេនាធិការបន្ថែមជួយដល់រាជរដ្ឋាភិបាលកម្ពុជា មាន បេសកកម្ម ការងារក្នុងការ ***សម្របសម្រួលដល់ការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍន៍តំបន់ទន្លេសាប*** ដូចបាន កំណត់ក្នុងព្រះរាជក្រឹត្យលេខ នស/រកត/0609/705 ចុះថ្ងៃទី 29 ខែមិថុនា ឆ្នាំ 2009 និងព្រះរាជក្រឹត្យលេខ នស/រកត/0310/258 ចុះថ្ងៃទី24 ខែមីនា ឆ្នាំ 2010 ស្តីពី ការកែសម្រួលមាត្រា 3 មាត្រា 5 មាត្រា 6 មាត្រា 9 មាត្រា 10 និង មាត្រា 12 នៃព្រះរាជក្រឹត្យលេខ នស/រកត/0609/705 ចុះថ្ងៃទី 29 ខែមិថុនា ឆ្នាំ 2009 ស្តីពីការបង្កើត **អាជ្ញាធរទន្លេសាប** ។

ជាមួយនឹងបេសកកម្មការងារ និងតួនាទីភារកិច្ចស្នូល **អាជ្ញាធរទន្លេសាប** បានរៀបចំបង្កើតឡើងនូវ **អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប** ដូចមានកំណត់ក្នុងអនុក្រឹត្យរបស់រាជរដ្ឋាភិបាលកម្ពុជា លេខ 166 អនក្របក ចុះថ្ងៃទី 30 ខែកក្កដា ឆ្នាំ 2009 សម្រាប់ដំណើរការការងារប្រចាំថ្ងៃ និងចាត់ការទូទៅលើការងារសម្របសម្រួល ទំនាក់ទំនង និងសហការរវាងក្រសួងស្ថាប័ន អាជ្ញាធរដែនដី អង្គការជាតិ អង្គការអន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល និងសង្គមស៊ីវិលនានា សម្រាប់ការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍន៍តំបន់ទន្លេសាបប្រកបដោយនិរន្តរភាព ។

យោងតាមមាត្រា 2 ជំពូកទី 2 នៃអនុក្រឹត្យ ដែលចែងពីតួនាទី និងភារកិច្ចរបស់អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប មានដូចខាងក្រោម ៖

- ទទួលបន្ទុកដឹកនាំ ចាត់ចែង និងសម្របសម្រួលរាល់សកម្មភាពការងារប្រចាំថ្ងៃ អាជ្ញាធរទន្លេសាប
- សិក្សាស្រាវជ្រាវ អំពីសក្តានុពលធនធានធម្មជាតិ ដែលមានក្នុងតំបន់ទន្លេសាប និងតំបន់ពាក់ព័ន្ធ
- សិក្សាស្រាវជ្រាវ ត្រួតពិនិត្យ វាយតម្លៃ និងតាមដាន លើការធ្វើអាជីវកម្ម និងការប្រើប្រាស់ធនធានធម្មជាតិ ដែលមានក្នុងតំបន់ទន្លេសាប និងតំបន់ពាក់ព័ន្ធ
- ប្រមូលទិន្នន័យ និងវិភាគនូវរាល់ព័ត៌មាន និងសកម្មភាពជាក់ស្តែង ដើម្បីរៀបចំផែនការយុទ្ធសាស្ត្រ ចំពោះមុខ និងយូរអង្វែង ជូនរាជរដ្ឋាភិបាល ក្នុងការកំណត់ទីតាំងគោលដៅបម្រើដល់កិច្ច អភិវឌ្ឍន៍ និង អភិរក្ស
- រៀបចំគោលនយោបាយ ទស្សនវិស័យ បេសកកម្មរបស់អាជ្ញាធរទន្លេសាប
- សម្របសម្រួល និងសហការ ជាមួយបណ្តាក្រសួងស្ថាប័ន អាជ្ញាធរដែនដីពាក់ព័ន្ធ អង្គការជាតិ អន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល និងសង្គមស៊ីវិលនានា លើរាល់សកម្មភាពទាក់ទងនឹងការគ្រប់គ្រង អភិរក្ស និង អភិវឌ្ឍន៍ក្នុងតំបន់ទន្លេសាបប្រកបដោយនិរន្តរភាព
- សហការ ជាមួយបណ្តាក្រសួងស្ថាប័ន អាជ្ញាធរដែនដីពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍នានា ដើម្បីរៀបចំគោល នយោបាយ ផែនការយុទ្ធសាស្ត្រ កម្មវិធីគម្រោងអភិរក្ស អភិវឌ្ឍន៍ផ្សេងៗ ដែលមាននៅក្នុងតំបន់ទន្លេសាប

- រៀបចំចងក្រងឯកសារទិន្នន័យ ព័ត៌មាន ដើម្បីអប់រំផ្សព្វផ្សាយ
- ធ្វើរបាយការណ៍ប្រចាំខែ ឆមាស និងប្រចាំឆ្នាំ ជូនប្រធានអាជ្ញាធរទន្លេសាប
- អនុវត្តន៍ភារកិច្ចផ្សេងៗ ដែលប្រធានអាជ្ញាធរទន្លេសាប ប្រគល់ជូន ។

## ២. រចនាសម្ព័ន្ធ និងការគ្រប់គ្រង

យោងតាមអនុក្រឹត្យ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ **អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប** ក្នុងមាត្រា 3 ជំពូក 3 ដែលចែងពីរចនាសម្ព័ន្ធ និងការគ្រប់គ្រង គឺមាននាយកដ្ឋានចំនួន 04 អមដោយការិយាល័យចំនួន 14 និងបានកំណត់ពីតួនាទី ភារកិច្ចទទួលខុសត្រូវតាមនាយកដ្ឋាន និងការិយាល័យ នីមួយៗដូចមានចែងក្នុងប្រកាសលេខ 025 អទស ចុះថ្ងៃទី 21 ខែ ធ្នូ ឆ្នាំ 2009 ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ការិយាល័យចំណុះបណ្តានាយកដ្ឋាន ក្រោមឱវាទអគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប ។ នាយកដ្ឋាន និងការិយាល័យស្ថិតក្រោមឱវាទ រួមមាន ៖

- នាយកដ្ឋានរដ្ឋបាល ផែនការ និងសហប្រតិបត្តិការ ការិយាល័យចំនួន 04
- នាយកដ្ឋានធនធានធម្មជាតិ ការិយាល័យចំនួន 04
- នាយកដ្ឋានត្រួតពិនិត្យការធ្វើអាជីវកម្ម និងអភិរក្ស ការិយាល័យចំនួន 03
- នាយកដ្ឋាននីតិកម្ម និងផ្សព្វផ្សាយ ការិយាល័យចំនួន 03

ជាក់ស្តែង ការរៀបចំកសាងផែនការសកម្មភាពប្រចាំឆ្នាំ 2018 របស់**អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរ ទន្លេសាប** ក្នុងបំណងឆ្លុះបញ្ចាំងឲ្យឃើញពីទិសដៅ និងសកម្មភាពការងារអាទិភាពប្រចាំឆ្នាំ ដើម្បីជម្រុញដល់ដំណើរការអនុវត្តផែនការយុទ្ធសាស្ត្ររយៈពេល 5 ឆ្នាំ (2016-2020) របស់អាជ្ញាធរទន្លេសាប ឲ្យទទួលបានជោគជ័យ តាមទិសដៅជាយុទ្ធសាស្ត្រទាំង 5 និងលើកកម្ពស់ប្រសិទ្ធភាពការងាររបស់អាជ្ញាធរទន្លេសាប ក្នុងបេសកកម្មស្នូល **សម្របសម្រួលដល់ការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍន៍តំបន់ទន្លេសាប ។**

# ផ្នែកទី ២

## វឌ្ឍនភាពការងារនៃផែនការសកម្មភាពប្រចាំឆ្នាំ 2017

### ១. សេចក្តីផ្តើម

ផែនការសកម្មភាពប្រចាំឆ្នាំ របស់អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប គឺជាផែនការសកម្មភាព ពង្រឹងប្រសិទ្ធភាពតួនាទីភារកិច្ចស្នូល និងការទទួលខុសត្រូវរបស់អាជ្ញាធរទន្លេសាប ជាពិសេសគាំទ្រដល់ដំណើរការអនុវត្តផែនការយុទ្ធសាស្ត្ររយៈពេល 5 ឆ្នាំ (2016-2020) របស់អាជ្ញាធរទន្លេសាប អោយសម្រេចបានជោគជ័យ ក្នុងការចូលរួមលើកកម្ពស់ដល់ការអនុវត្តប្រកបដោយប្រសិទ្ធភាពនូវគោលនយោបាយអាទិភាព របស់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីឈានទៅសម្រេចគោលដៅអភិវឌ្ឍន៍សហវត្សរ៍កម្ពុជា ។ ផែនការសកម្មភាពប្រចាំឆ្នាំ 2017 បានកំណត់ពីសកម្មភាពការងារអាទិភាពរបស់អគ្គលេខាធិការដ្ឋាន និងអង្គភាពក្រោមឱវាទអាជ្ញាធរទន្លេសាប ដើម្បីអនុវត្តសម្រេចនូវគោលបំណង (Objective) លទ្ធផល (Outcome) និងធាតុចេញ (Output) ដោយប្រើប្រាស់នូវកញ្ចប់ថវិកាជាតិប្រចាំឆ្នាំ 2017 ។

### ២. វឌ្ឍនភាពការងារនៃផែនការសកម្មភាពប្រចាំឆ្នាំ 2017

### ២.១. លទ្ធផលសម្រេចបានសំខាន់ៗ

ក្រោយពីផែនការសកម្មភាពប្រចាំឆ្នាំ 2017 របស់អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប ត្រូវបានអនុម័តដាក់ឲ្យអនុវត្តនាដើមឆ្នាំ 2017 ។ អគ្គលេខាធិការដ្ឋាននៃអាជ្ញាធរទន្លេសាប បានរៀបចំធ្វើការផ្សព្វផ្សាយដល់ក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធ ដើម្បីចូលរួមសហការ និងអនុវត្តន៍ឲ្យមានប្រសិទ្ធភាព ។

ជាក់ស្តែងបន្ទាប់ពីធ្វើការតាមដានត្រួតពិនិត្យ និងវាយតម្លៃ ពីលទ្ធផលនៃការអនុវត្តផែនការសកម្មភាពប្រចាំឆ្នាំ 2017 អស់រយៈពេល ១ ឆ្នាំ បានបង្ហាញឲ្យឃើញថា ៖ គម្រោងសកម្មភាពចំនួន ៨១ សកម្មភាព ដែលមានក្នុងផែនការសកម្មភាពប្រចាំឆ្នាំ 2017 គឺអនុវត្តបាន ៧១ សកម្មភាព សម្រេចបាន ៩០ ភាគរយ និងនៅសល់ ១០ សកម្មភាព ស្មើនឹង ១០ ភាគរយ បាននិងកំពុងបន្តអនុវត្តន៍ ។

សកម្មភាពចុះសិក្សាស្រាវជ្រាវ និងប្រមូលព័ត៌មានទិន្នន័យរបស់មន្ត្រីថ្នាក់ដឹកនាំ និងមន្ត្រីបច្ចេកទេស នៅតាមគម្រោងសកម្មភាពនីមួយៗ ត្រូវបានធ្វើការតាមដានពីការអនុវត្តជាប្រចាំ តាមរយៈរបាយការណ៍លទ្ធផលនៃការចុះអនុវត្តការងារជាក់ស្តែង ជាពិសេសប្រជុំពិនិត្យតាមដានការអនុវត្តរយៈពេល ៦ ខែ ដើម្បីពិនិត្យពីចំណុចខ្លាំងខ្សោយ ឧបសគ្គ និងបញ្ហាប្រឈមនានា ក្នុងការបង្កើនប្រសិទ្ធភាពបន្តអនុវត្តន៍សកម្មភាពឲ្យបានជោគជ័យ ។ សកម្មភាពចុះសិក្សាស្រាវជ្រាវ តាមគម្រោងសកម្មភាពនីមួយៗ ក៏ត្រូវបានរំលេចចេញនូវឯកសារបច្ចេកទេសលទ្ធផលបន្ទាប់ពីបញ្ចប់ការចុះស្រាវជ្រាវ ដែលបាននិងកំពុងអនុវត្តន៍ ដោយឆ្លុះបញ្ចាំងរបកគំហើញ អំពីសក្តានុពល និងផលប៉ះពាល់មកលើបរិយាកាសសេដ្ឋកិច្ច សង្គម បរិស្ថានធនធានធម្មជាតិ និងការគ្រប់គ្រងតំបន់បឹងទន្លេសាប ។ ក្នុងរបកគំហើញលទ្ធផលសិក្សាតាមគម្រោងសកម្មភាពនីមួយៗនេះ **អាជ្ញាធរទន្លេសាប** ក៏បានរំលេចចេញនូវសមិទ្ធិផលស្នាដៃរួម ដូចជា៖ **កម្រងរបាយការណ៍បច្ចេកទេសលេខទី ១ ឆ្នាំ ២០១៧ អំពីស្ថានភាពសេដ្ឋកិច្ច សង្គម បរិស្ថានធនធានធម្មជាតិ និងការគ្រប់គ្រងតំបន់បឹងទន្លេសាប** ដោយក្រុមការងារបច្ចេកទេស ដែលត្រូវបានបង្កើតឡើងស្រប

តាមសេចក្តីសម្រេចលេខ ២២២/១៧ អទស ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១៧ និង**ទស្សនាវដ្តីប្រចាំឆ្នាំស្តីពីសកម្មភាពការងាររបស់អាជ្ញាធរទន្លេសាប** ។

របាយការណ៍លទ្ធផលរបកគំហើញចុះសិក្សាស្រាវជ្រាវ ក្រុមការងារមន្ត្រីបច្ចេកទេស បាននិងកំពុងប្រើប្រាស់ជាប្រយោជន៍ក្នុងការឈានទៅរៀបចំឯកសារបច្ចេកទេស ដែលមានលក្ខណៈជាយុទ្ធសាស្ត្រ ផែនការ កម្មវិធី និងគម្រោងសកម្មភាព ដើម្បីដាក់ជូនរាជរដ្ឋាភិបាលពិនិត្យ និងធ្វើការសម្រេចចិត្ត ក្នុងការកំណត់ដាក់បញ្ចូលជាក្របខ័ណ្ឌគោលនយោបាយជាតិរួម សម្រាប់ការគ្រប់គ្រង និងអភិវឌ្ឍន៍តំបន់បឹងទន្លេសាប និងតំបន់ពាក់ព័ន្ធប្រកបដោយចីរភាព ។

សកម្មភាពចុះសិក្សា រួមនិងលទ្ធផលការងារតាមគម្រោងសកម្មភាពនីមួយៗ មន្ត្រីថ្នាក់ដឹកនាំ និងមន្ត្រីបច្ចេកទេសស្ថិតក្រោមឱវាទ បានខិតខំប្រឹងប្រែងយកចិត្តទុកដាក់បង្កើនពង្រឹងការយល់ដឹង និងសហការចែករំលែករាល់ព័ត៌មាន ទិន្នន័យ និងចំណេះដឹងបទពិសោធន៍ពីគ្នាទៅវិញទៅមក ដើម្បីជម្រុញប្រសិទ្ធភាពការងាររបស់អង្គភាព ក៏ដូចជាចូលរួមគាំទ្រដល់គោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជាទាំងមូល ។ ជាពិសេសមន្ត្រីថ្នាក់ដឹកនាំ និងមន្ត្រីបច្ចេកទេស ក៏បានដើរតួនាទីក្នុងនាមជាអង្គភាពសម្របសម្រួល បានប្រើប្រាស់នូវលទ្ធផលរបកគំហើញពីការងារសិក្សាស្រាវជ្រាវមកធ្វើជាមូលដ្ឋាន សម្រាប់ជាទឡ្ហីករណ៍ធ្វើការផ្លាស់ប្តូរយោបល់ក្នុងអង្គសិក្ខាសាលា ប្រជុំនិងវេទិកានានា ចែករំលែកការយល់ដឹងតាមបណ្តាញទំនាក់ទំនងគេហទំព័រ បណ្តាញសង្គម ដែលតែងតែធ្វើបច្ចុប្បន្នភាពព័ត៌មាន ទិន្នន័យជាប្រចាំ អំពីសកម្មភាពការងាររបស់អង្គភាព និងចែករំលែកបទពិសោធន៍លើកកម្ពស់ការយល់ដឹងជូនដល់ភាគីពាក់ព័ន្ធនានាទាំងក្នុងកម្រិតថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ ថ្នាក់តំបន់ និងអន្តរជាតិ ។ ម្យ៉ាងទៀត ការលើកកម្ពស់ជម្រុញការផ្សព្វផ្សាយការយល់ដឹងពីគោលនយោបាយជាតិរបស់រាជរដ្ឋាភិបាលកម្ពុជា មន្ត្រីថ្នាក់ដឹកនាំរបស់អាជ្ញាធរទន្លេសាប បានប្រើប្រាស់នូវចំណេះដឹង និងបទពិសោធន៍ការងារ ចូលរួមជាមួយក្រុមការងារស្នូលដែលជាសមាជិករាជរដ្ឋាភិ បាលកម្ពុជា ចុះធ្វើការផ្សព្វផ្សាយ ជូនដល់ប្រជាពលរដ្ឋ និងសហគមន៍មូលដ្ឋាននៅថ្នាក់ក្រោមជាតិ ។

ក្នុងកិច្ចសហការ មន្ត្រីថ្នាក់ដឹកនាំ និងមន្ត្រីបច្ចេកទេសតំណាងឲ្យអង្គភាព បានទំនាក់ទំនង និងទទួលជួបពិភាក្សាការងារកិច្ចសហប្រតិបត្តិការជាមួយបណ្តាក្រសួង ស្ថាប័ន និងភាគីជំនួយជាតិ និងអន្តរជាតិនានា (ចិន, ជប៉ុន, France, USAID, IUCN, JICA, China-ASEAN Environmental Cooperation Center) ក្នុងការចូលរួមសមាហរណកម្មការយល់ដឹង និងចែករំលែកនូវព័ត៌មាន ទិន្នន័យបង្ហាញពីលទ្ធផលសកម្មភាពសិក្សាស្រាវជ្រាវរបស់អង្គភាព ក្នុងកិច្ចប្រជុំ ប្រឹក្សាយោបល់ ជាពិសេសជាមួយដៃគូគម្រោងពាក់ព័ន្ធ ដូចជា ៖ គម្រោងគ្រប់គ្រងធនធានទឹកចម្រុះអាងស្ទឹងសែន, គម្រោងបង្កើតវេទិកាអភិរក្សបរិស្ថានតំបន់បឹងទន្លេសាប, គម្រោងបម្រែបម្រួលអាកាសធាតុ និងអភិបាលកិច្ចទឹកក្នុងព្រះរាជាណាចក្រកម្ពុជា, គម្រោងកិច្ចសហប្រតិបត្តិការគ្រប់គ្រងធនធានទឹកចម្រុះឆ្លងដែនមេគង្គរវាងបឹងទន្លេសាប (កម្ពុជា) និងអាងសុងក្លា (ថៃ), គម្រោងវាយតម្លៃផលចាប់បឹងទន្លេសាប ។ ក្នុងនោះដែរ ក៏បានចែករំលែកនូវព័ត៌មាន និងចំណេះដឹងដល់អ្នកសិក្សាស្រាវជ្រាវ តាមរយៈវេទិកាសន្និសីទជាតិ និងអន្តរជាតិ រួមមាន ៖ International Symposium on Flood Pulse Ecosystems, The 2nd International Symposium on Conservation and Management of Tropical Lakes and Joint Coordination Committee Meeting, Exchange Lake Environmental Management ។

ក្នុងដំណើរការងារប្រចាំឆ្នាំ ២០១៧ នេះ អាជ្ញាធរទន្លេសាប ក៏បានគិតគូរពិចារណាប្រសិទ្ធភាពនៃការចងក្រងគោលការណ៍ពិពណ៌នាពីតួនាទីមុខតំណែងមន្ត្រីក្នុងរចនាសម្ព័ន្ធគ្រប់គ្រងរបស់អង្គភាព និងបានផ្តល់ការលើកទឹកចិត្តដល់មន្ត្រីថ្នាក់ដឹកនាំនិងមន្ត្រីបច្ចេកទេស ដែលសកម្មជាមួយការងារ និងអតីតភាពការងារចំនួនសរុប ៤៥ រូប ក្នុងនោះធ្វើការសម្របសម្រួលក្របខ័ណ្ឌជូនមន្ត្រីរាជការចំនួន ១៦ រូប ឋានន្តរស័ក្តិ ៤៤ រូប កាំប្រាក់ ៨៩ រូប និងមេដាយការងារ ៤១ រូប ។ ចំពោះការបង្កើនសមត្ថភាពចំណេះដឹងដល់មន្ត្រីរបស់អង្គភាព បានបញ្ជូនមន្ត្រីចំនួន ០១ ចូលរួមវគ្គបណ្តុះបណ្តាលនៅក្រៅប្រទេសចំនួន ០១ វគ្គ និងបើកវគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាពក្នុងស្រុកបានចំនួន ០៤ វគ្គ មានការចូលរួមពីមន្ត្រីចំនួនជាមធ្យម ៣០ នាក់ រួមមាន ៖ ការគ្រប់គ្រងរដ្ឋបាលសម្រាប់មន្ត្រីថ្មី, ជំនាញក្នុងការប្រាស្រ័យទាក់ទង, ចំនេះដឹងជាមូលដ្ឋានស្តីពីការតាមដាន និងវាយតម្លៃគម្រោង/កម្មវិធីវគ្គ ១, ផ្សព្វផ្សាយការយល់ដឹងពីការគ្រប់គ្រងថវិកា និងហិរញ្ញវត្ថុ, ចំណេះដឹងជាមូលដ្ឋាន ស្តីពីការតាមដាននិងវាយតម្លៃគម្រោង/កម្មវិធីវគ្គ ២, វិធីសាស្ត្រសរសេររបាយការណ៍គម្រោង/កម្មវិធី។

## ២.២. លទ្ធផលរួមគាំទ្រការអនុវត្តផែនការយុទ្ធសាស្ត្រ ៥ ឆ្នាំ (២០១៦-២០២០)

ផ្សាភ្ជាប់ជាមួយភារកិច្ចទទួលខុសត្រូវក្នុងឆ្នាំ ២០១៧ អាជ្ញាធរទន្លេសាប បានកំណត់នូវសកម្មភាពការងារក្នុងផែនការសកម្មភាពការងារប្រចាំឆ្នាំ ដែលឆ្លើយតបទៅនិងតួនាទីភារកិច្ចការងារទទួលខុសត្រូវស្នូលរបស់អង្គភាព និងគាំទ្រដល់ដំណើរការអនុវត្តផែនការយុទ្ធសាស្ត្ររយៈពេល ៥ ឆ្នាំ របស់អង្គភាពឲ្យទទួលបានជោគជ័យនៅក្នុងឆ្នាំ (២០១៦-២០២០) ។

បន្ទាប់ពីពិនិត្យតាមដានរាល់គម្រោងសកម្មភាពការងារប្រតិបត្តិក្នុងរយៈពេល ១ ឆ្នាំ លទ្ធផលរួមក្នុងឆ្នាំ ២០១៧ បានចូលរួមគាំទ្រដល់ផែនការយុទ្ធសាស្ត្រនៅក្នុង **ទិសដៅទី ១** គឺបានបន្តពង្រីកការយកចិត្តទុកដាក់សម្របសម្រួល និងសហការផ្សព្វផ្សាយការយល់ដឹង អំពីគោលនយោបាយ បទបញ្ញត្តិរបស់រាជរដ្ឋាភិបាល ជូនទៅដល់មន្ត្រីពាក់ព័ន្ធថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងសហគមន៍មូលដ្ឋានពាក់ព័ន្ធជាមួយច្បាប់ ស្តីពីការគ្រប់គ្រងធនធានទឹកនៅក្នុងព្រះរាជាណាចក្រកម្ពុជា អមនិងបទបញ្ញត្តិអនុក្រឹត្យមួយចំនួនដូចជា ៖ នីតិវិធីការបង្កើត ការរំលាយចោល និងការកំណត់តួនាទី និងភារកិច្ចនៃសហគមន៍កសិករប្រើប្រាស់ទឹក, ការគ្រប់គ្រងអាងទន្លេ និងច្បាប់បទបញ្ញត្តិពាក់ព័ន្ធការគ្រប់គ្រង និងការពារបរិស្ថានធនធានធម្មជាតិ សំដៅដល់កិច្ចការពារ និងទប់ស្កាត់ផលប៉ះពាល់ដល់ធនធានបរិស្ថានធនធានធម្មជាតិនៅក្នុងតំបន់បឹងទន្លេសាប និងតំបន់ពាក់ព័ន្ធ ។ **ទិសដៅទី ២** ពង្រឹងការយល់ដឹងជាមូលដ្ឋាន អំពីការគ្រប់គ្រង បានជម្រុញសកម្មភាពចុះសិក្សាស្រាវជ្រាវ និងប្រមូលព័ត៌មាន ទិន្នន័យ ដែលពាក់ព័ន្ធសេដ្ឋកិច្ច សង្គម បរិស្ថានធនធានធម្មជាតិ និងការគ្រប់គ្រងតំបន់បឹងទន្លេសាប ដើម្បីធ្វើជាមូលដ្ឋានពង្រីកការយល់ដឹង និងបានប្រើប្រាស់ជាប្រយោជន៍ ផ្សេងៗទៀត ដល់ការរៀបចំក្របខ័ណ្ឌគោលនយោបាយជាតិ ផែនការ យុទ្ធសាស្ត្រ និងសកម្មភាព ឬគម្រោងកម្មវិធីនានា រួមជាមួយការចែករំលែកការយល់ដឹង អំពីសក្តានុពល និងផលប៉ះពាល់ ឈានទៅការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍន៍ដោយចិរភាពនៅតំបន់បឹងទន្លេសាប និងតំបន់ពាក់ព័ន្ធ ។ **ទិសដៅទី ៣** ជាមួយការយកចិត្តទុកដាក់សម្របសម្រួល កសាងផែនការ និងគ្រប់គ្រង តាមរយៈមន្ត្រីថ្នាក់ដឹកនាំ និងមន្ត្រីបច្ចេកទេសតំណាងអង្គភាព បានចូលរួមសម្របសម្រួលក្នុងទស្សនៈកិច្ចសិក្សាផ្លាស់ប្តូរបទពិសោធន៍ ចែករំលែកការយល់ដឹងជាមួយបណ្តាក្រសួងស្ថាប័ន ជាតិ ថ្នាក់ក្រោមជាតិ សហគមន៍មូលដ្ឋាន ថ្នាក់តំបន់ និងអន្តរជាតិ ។ លទ្ធផលស្រាវជ្រាវ រួមជាមួយលទ្ធផលអនុវត្តន៍គម្រោងសកម្មភាពការងារប្រចាំឆ្នាំរបស់អាជ្ញាធរទន្លេសាប គឺបានពង្រឹងការ

យកចិត្តទុកដាក់តាមដានជាប្រចាំ ក្នុងការធ្វើបច្ចុប្បន្នភាពចងក្រង និងវាយតម្លៃសម្រាប់កំណត់ទិសដៅអនុវត្តន៍បន្ត ដើម្បីរៀបចំនូវផែនការសកម្មភាពការងារប្រចាំឆ្នាំបន្តបន្ទាប់។ ក្នុងនោះដែរ**អាជ្ញាធរទន្លេសាប** ចុងឆ្នាំ ២០១៧ ក៏បាន រំលេចនូវឯកសាររបាយការណ៍បច្ចេកទេសលេខទី ១ សិក្សាស្រាវជ្រាវ អំពីស្ថានភាពសេដ្ឋកិច្ចសង្គម បរិស្ថានធនធានធម្មជាតិ និងការគ្រប់គ្រងតំបន់បឹងទន្លេសាប រួមជាមួយទស្សនាវដ្តី ស្តីពីសកម្មភាពការងារប្រចាំឆមាសរបស់អាជ្ញាធរទន្លេសាប ។ **ទិសដៅទី ៤** ការជម្រុញលើកកម្ពស់ដល់ការទំនាក់ទំនងកិច្ចសហប្រតិបត្តិការ និងការកសាងសមត្ថភាព មន្ត្រីបច្ចេកទេសនាយកដ្ឋានរដ្ឋបាល ផែនការ និងសហប្រតិបត្តិការ និងនាយកដ្ឋាននីតិកម្ម និងផ្សព្វផ្សាយ បាននិងកំពុងតែជម្រុញការទទួលខុសត្រូវ ដោយយកចិត្តទុកដាក់រៀបចំឲ្យបាននូវក្របខ័ណ្ឌការងារច្បាស់លាស់ អំពីផែនការប្រាស្រ័យទំនាក់ទំនង ដើម្បីផ្សព្វផ្សាយចែករំលែកការយល់ដឹង ពីវឌ្ឍនភាពសកម្មភាពការងារ និងប្រសិទ្ធភាពការងារទទួលខុសត្រូវរបស់អាជ្ញាធរទន្លេសាប ក្នុងការបង្កើនទំនាក់ទំនងជាមួយក្រសួងស្ថាប័នទាំងកម្រិតថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ សហគមន៍មូលដ្ឋាន និងថ្នាក់តំបន់ ។ **ទិសដៅទី ៥** ការជម្រុញដល់កិច្ចការប្រតិបត្តិរបស់អាជ្ញាធរទន្លេសាប អោយប្រកបដោយប្រសិទ្ធភាព និងនិរន្តរភាព ស្របតាមតួនាទីភារកិច្ចទទួលខុសត្រូវរបស់អង្គភាព ចំពោះរដ្ឋាភិបាលប្រគល់ជូន រាល់សកម្មភាពការងារស្នូលអង្គភាព និងអគ្គលេខាធិការដ្ឋាន ដែលរួមមានការងាររដ្ឋបាលទូទៅ ការគ្រប់គ្រងបុគ្គលិក ហិរញ្ញវត្ថុ ការងារសម្របសម្រួលសហប្រត្តិបត្តិការ និងការងារបច្ចេកទេសស្រាវជ្រាវ រៀបចំឯកសារបច្ចេកទេសផ្សេងៗ ត្រូវបានឆ្លុះបញ្ចាំង និងកំណត់នៅក្នុងផែនការយុទ្ធសាស្ត្ររយៈពេល ៥ ឆ្នាំ និងផែនការសកម្មភាពការងារប្រចាំឆ្នាំរបស់អាជ្ញាធរទន្លេសាប ។ ក្នុងការអនុវត្តសកម្មភាពការងារផែនការសកម្មភាពប្រចាំឆ្នាំ ក៏បានដើរតួនាទីក្នុងការសម្របសម្រួលបង្កើនកិច្ចសហការកៀគរប្រភពថវិកា និងជំនួយគាំទ្រដល់ដំណើរការងារប្រចាំថ្ងៃរបស់អង្គភាព ក្នុងនោះក៏បានយកចិត្តទុកដាក់តាមដានត្រួតពិនិត្យ និងវាយតម្លៃពីលទ្ធផលអនុវត្តន៍ការងារ ដើម្បីឆ្លុះបញ្ចាំងពីវឌ្ឍនភាព និងប្រសិទ្ធភាពការងារពីមួយឆ្នាំទៅមួយឆ្នាំ ។ ជាមួយសកម្មភាពភាពបង្កឲ្យមានសុខដុមនីយកម្មនៅក្នុងអង្គភាពបម្រើការងារ ក៏បានយកចិត្តទុកដាក់ខ្ពស់បំផុតក្នុងការលើកទឹកចិត្តចំពោះមន្ត្រីថ្នាក់ដឹកនាំ និងមន្ត្រីរដ្ឋបាលបច្ចេកទេសក្រោមឱវាទ និងផ្តល់ការបណ្តុះបណ្តាលពង្រឹងសមត្ថភាព ដើម្បីប្រសិទ្ធភាពការងាររបស់អាជ្ញា ធរទន្លេសាប ។

## ៣. មេរៀន និងបទពិសោធន៍ការអនុវត្តផែនការសកម្មភាពប្រចាំឆ្នាំ 2017

ឆ្លងតាមការត្រួតពិនិត្យ និងវាយតម្លៃអំពីការអនុវត្តផែនការសកម្មភាពប្រចាំឆ្នាំ 2017 របស់អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប បានឆ្លុះបញ្ចាំងឲ្យឃើញពីបញ្ហាធំៗមួយចំនួន ដែលជាឧបសគ្គ/បញ្ហាប្រឈមចំពោះដំណើរការអនុវត្តផែនការសកម្មភាព និងមិនអាចឈានទៅសម្រេចបានជោគជ័យទាំងស្រុងតាមការរំពឹងទុកដូចបានលើកឡើងក្នុងផែនការសកម្មភាពការងារប្រចាំឆ្នាំ ។ ឧបសគ្គ/បញ្ហាប្រឈមទាំងអស់នេះគឺជាមេរៀនបទពិសោធន៍សម្រាប់ធ្វើការកែតម្រូវ និងរកវិធីដោះស្រាយអោយបានកាន់តែប្រសើរឡើងនៅក្នុងដំណាក់កាលអនុវត្តការងារជាបន្តបន្ទាប់ទៀត មានជាអាទិ៍ ៖

- ធនធានមនុស្សប្រកបដោយចំណេះដឹង និងជំនាញឲ្យបានស៊ីជម្រៅទាំងបរិមាណ និងគុណភាព នៅពុំទាន់បានបំពេញតាមតម្រូវការ និងសមស្របតាមស្ថានការណ៍ការងារជាក់ស្តែង ក្នុងការងារបច្ចេកទេសស្រាវជ្រាវ និងធ្វើការវិភាគ

- សម្ភារៈបច្ចេកទេសប្រើប្រាស់ធ្វើការសិក្សាស្រាវជ្រាវ និងធ្វើពិសោធន៍ នៅខ្វះខាត និងពុំទាន់ទំនើបកម្ម តាមរបទការងារជាលក្ខណៈស្តង់ដា និងតាមបែបប្រព័ន្ធតិចណូឡូជី
- ការអនុវត្តថវិកាកម្មវិធី ក្នុងក្របខ័ណ្ឌកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ ជាមួយក្រសួងជំនាញ នៅមានកម្រិត
- ការចូលរួម និងការផ្តល់កិច្ចសហការពីមន្ត្រីបុគ្គលិកពាក់ព័ន្ធទាំងកម្រិតថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងសហគមន៍មូលដ្ឋាន ក្នុងការផ្តល់ព័ត៌មាន ទិន្នន័យ មិនទាន់បានទូលំទូលាយ នៅមានកម្រិត
- ព័ត៌មាន ទិន្នន័យ បានមកពីការសិក្សា នៅមានកម្រិត និងការផ្សព្វផ្សាយចែករំលែកការយល់ដឹងនៅមិនបានអនុវត្តអោយបានទូលំទូលាយ
- ទីតាំងចំណុចដៅសិក្សាមួយចំនួន មានស្ថានភាពពិបាកបង្កហានិភ័យ ក្នុងការទទួលបានព័ត៌មាន ដូចជាទីតាំងបង្កបទល្មើសជលផល ព្រៃលិចទឹក អាកាសធាតុមិនល្អ និងមធ្យោបាយចុះសិក្សា
- ចំណេះដឹងសហគមន៍មូលដ្ឋាន នៅមានកម្រិត រួមជាមួយស្ថានភាពលំបាកក្នុងជីវភាពរស់នៅប្រចាំថ្ងៃ ធ្វើឲ្យពិបាកក្នុងការទទួលបានព័ត៌មាន ទិន្នន័យ
- គម្រោងសកម្មភាពមួយចំនួនក្នុងផែនការសកម្មភាពដែលស្នើសុំអនុវត្តមិនទាន់យល់ស៊ីជម្រៅក្នុងការវិភាគអំពីលក្ខណៈ SWOT (ចំណុចខ្លាំង ខ្សោយ ឱកាស និងពេលវេលា) ឬ SMART (មានភាពជាក់ស្តែង ដែលវាស់វែងបាន ដែលសម្រេចបាន មានភាពប្រាកដប្រជា និងពេលវេលាត្រឹមត្រូវ)

# ផ្នែកទី ៣

## ផែនការសកម្មភាពប្រចាំឆ្នាំ 2018 របស់អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប

### ១. លក្ខណៈទូទៅ

ផែនការសកម្មភាពប្រចាំឆ្នាំ 2018 របស់អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប គឺជាសកម្មភាពការងារលម្អិត សម្រាប់ប្រតិបត្តិអនុវត្តការងារជាក់ស្តែង ដោយមានការចូលរួមសហការពីបណ្តាក្រសួងស្ថាប័នទាំងក្នុងកម្រិតថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ ថ្នាក់តំបន់ សង្គមស៊ីវិល អង្គការជាតិ-អន្តជាតិ និងដៃគូអភិវឌ្ឍន៍នានា ដើម្បីជម្រុញប្រសិទ្ធភាពនៃការអនុវត្តផែនការយុទ្ធសាស្ត្រអាជ្ញាធរទន្លេសាបរយៈពេល 5 ឆ្នាំ (2016-2020) ឲ្យទទួលបានជោគជ័យ ។

ជារួម ផែនការសកម្មភាពប្រចាំឆ្នាំ ត្រូវបានរៀបចំឡើងដោយបន្សីជាមួយគម្រោងសកម្មភាពការងារអាទិភាពសំខាន់ៗ (ដូចក្នុងតារាង 1) នៃផែនការយុទ្ធសាស្ត្ររយៈពេល 5 ឆ្នាំ របស់អាជ្ញាធរទន្លេសាប (2016-2020) ។ ជាពិសេសស្របទៅតាមតួនាទីភារកិច្ចការងារទទួលខុសត្រូវ ដូចបានកំណត់ក្នុងអនុក្រឹត្យ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប ដើម្បីពង្រឹងប្រសិទ្ធភាពការងារ និងគាំទ្រដល់បេសកកម្មការងារស្នូលរបស់អាជ្ញាធរទន្លេសាប ក្នុងការសម្របសម្រួល ដល់ការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍន៍តំបន់ទន្លេសាប ប្រកបដោយនិរន្តរភាព ។

### ២. សកម្មភាពការងារប្រចាំឆ្នាំ 2018 របស់អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប

**ទិសដៅការងារទី** ១. ពង្រឹងគោលនយោបាយ បទបញ្ញត្តិ និងស្ថាប័ន

**លទ្ធផលរំពឹងទុក** ១. គោលនយោបាយ សម្រាប់ការណែនាំអភិបាលកិច្ចទឹក និងសកម្មភាពការងារអាជ្ញាធរទន្លេសាប

**គម្រោងសកម្មភាព** ១.១. លើកកម្ពស់គោលនយោបាយគ្រប់គ្រងធនធានទឹកឲ្យបានទូលំទូលាយនៅប្រទេសកម្ពុជា រួមទាំងនៅថ្នាក់តំបន់ ថ្នាក់ជាតិ និងនៅតំបន់ទន្លេសាប

1. ផ្សព្វផ្សាយ និងបង្កើនការយល់ដឹងគោលនយោបាយគ្រប់គ្រងធនធានទឹកឲ្យបានទូលំទូលាយ ដល់មន្ត្រី អ.ទ.ស

**គម្រោងសកម្មភាព** ១.២. សម្របសម្រួលបញ្ជ្រាបផែនការយុទ្ធសាស្ត្រគ្រប់គ្រងតំបន់ទន្លេសាប ក្នុងគោលនយោបាយយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ

2. កំណត់រាល់សូចនាករជាធាតុចូលសំខាន់ៗក្នុងផែនការយុទ្ធសាស្ត្រគ្រប់គ្រងតំបន់ទន្លេសាប

**គម្រោងសកម្មភាព** ១.៣. សម្របសម្រួលបញ្ជ្រាបផែនការយុទ្ធសាស្ត្រគ្រប់គ្រងតំបន់ទន្លេសាប ក្នុងគោលនយោបាយយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ

3. កំណត់ពីសូចនាករ និងទស្សនទានដែលជាធាតុចូលសំខាន់នៃគោលការណ៍គ្រប់គ្រងធានធានទឹកចម្រុះ សម្រាប់ការអភិវឌ្ឍន៍និងអភិរក្សតំបន់ទន្លេសាបប្រកបដោយចីរភាព

**លទ្ធផលរំពឹងទុក** ២. បទបញ្ញត្តិអភិបាលកិច្ចទឹកត្រូវបានបង្កើតឡើងនៅតំបន់ទន្លេសាប

**គម្រោងសកម្មភាព** ២.១. សម្របសម្រួល និងប្រតិបត្តិតាមរាល់បទបញ្ញត្តិពាក់ព័ន្ធនឹងច្បាប់ធនធានទឹក និងក្របខ័ណ្ឌក្នុងការគ្រប់គ្រងអាងទន្លេរបស់ព្រះរាជាណាចក្រកម្ពុជា

4. ផ្សព្វផ្សាយ និងបង្កើនការយល់ដឹងពីបទបញ្ញត្តិពាក់ព័ន្ធនឹងច្បាប់គ្រប់គ្រងធនធានទឹក

**គម្រោងសកម្មភាព** ២.២. កំណត់ដែនវិសាលភាពនៃតំបន់ទន្លេសាប (ព្រះរាជក្រឹត្យ មាត្រា ២)

5. បច្ចុប្បន្នភាពការកំណត់ដែនវិសាលភាពនៃតំបន់ទន្លេសាប (ព្រះរាជក្រឹត្យ មាត្រា ២)

**លទ្ធផលរំពឹងទុក** ៣. រាល់ធាតុសំខាន់ៗផ្នែកច្បាប់បទដ្ឋានគតិយុត្ត និងតួនាទីភារកិច្ចទទួលខុសត្រូវរបស់អាជ្ញាធរទន្លេសាប ត្រូវបានប្រតិបត្តិ និងបង្កើនប្រសិទ្ធភាពការងារ

**គម្រោងសកម្មភាព** ៣.១. ចាត់ចែងរៀបចំដំណើរការការងារឲ្យបានទៀងទាត់ (ប្រជុំ សិក្ខាសាលា...) ស្របតាមលក្ខន្តិកៈការងារពាក់ព័ន្ធភារកិច្ចរបស់អាជ្ញាធរទន្លេសាប

6. រៀបចំប្រជុំផ្ទៃក្នុងប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ ពីដំណើរការ និងការប្រព្រឹត្តិទៅរបស់អាជ្ញាធរទន្លេសាបរៀបចំសិក្ខាសាលាផ្សព្វផ្សាយដល់អ្នកពាក់ព័ន្ធតាមការចាំបាច់ពីដំណើរលទ្ធផលការងារក្នុងការគ្រប់គ្រង អភិវឌ្ឍន៍ និងអភិរក្ស

**គម្រោងសកម្មភាព** ៣.២. សម្របសម្រួល និងសហការជិតស្និទជាមួយក្រសួងស្ថាប័នជំនាញ ក្នុងការបង្កើនប្រសិទ្ធភាពការអនុវត្តច្បាប់ បទដ្ឋានគតិយុត្តពាក់ព័ន្ធការលើកកម្ពស់ការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍន៍ធនធានធម្មជាតិ និងប្រព័ន្ធអេកូឡូស៊ីតំបន់បឹងទន្លេសាប

7. សម្របសម្រួល និងសហការជាមួយស្ថាប័នជំនាញដើម្បីប្រមូល និងចងក្រងបទដ្ឋានគតិយុត្ត/ច្បាប់នានាពាក់ព័ន្ធក្នុងកិច្ចការងារគ្រប់គ្រង និងអភិវឌ្ឍន៍ធនធានធម្មជាតិ និងបរិស្ថាន
8. សម្របសម្រួល និងសហការជាមួយស្ថាប័នជំនាញធ្វើការផ្សព្វផ្សាយបង្កើនការយល់ដឹងអំពីបទបញ្ញត្តិពាក់ព័ន្ធនឹងការគ្រប់គ្រងធនធានជលផល
9. សម្របសម្រួល និងសហការជាមួយស្ថាប័នជំនាញធ្វើការផ្សព្វផ្សាយបង្កើនការយល់ដឹងអំពីបទបញ្ញត្តិពាក់ព័ន្ធនឹងការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន
10. បញ្ជ្រៀបការយល់ដឹងយេនឌ័រ

**គម្រោងសកម្មភាព** ៣.៣. បន្តស្មារតីចូលរួមអនុវត្តន៍បទដ្ឋានគតិយុត្ត ក្នុងកិច្ចការការពារដែនព្រៃលិចទឹកជុំវិញតំបន់ទន្លេសាប (តំបន់ ៣)

11. ចុះអធិការកិច្ចដែនព្រៃលិចទឹកដើម្បីសហការ និងការពារដែនព្រៃលិចទឹក (តំបន់៣)

**ទិសដៅការងារទី** ២. ពង្រឹងការយល់ដឹងជាមូលដ្ឋានអំពីការគ្រប់គ្រងទន្លេសាប

**លទ្ធផលរំពឹងទុក** ៤. មូលដ្ឋានទិន្នន័យសេដ្ឋកិច្ច សង្គមកិច្ច បរិស្ថាន និងធនធានធម្មជាតិតំបន់ទន្លេសាប និងតំបន់ពាក់ព័ន្ធ ត្រូវបានពង្រឹងក្នុងការប្រមូលចងក្រង និងផ្សព្វផ្សាយ

**គម្រោងសកម្មភាព** ៤.១.សិក្សាស្រាវជ្រាវពីស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច បរិស្ថាន និងធនធានធម្មជាតិតំបន់ទន្លេសាបនិងតំបន់ពាក់ព័ន្ធ

12. សិក្សាស្រាវជ្រាវពីស្ថានភាព និងសក្តានុពលទេសចរណ៍ធម្មជាតិនៅតំបន់បឹងទន្លេសាប
13. សិក្សាស្រាវជ្រាវ និងលើកកំពស់ការយល់ដឹងពីការគ្រប់គ្រងកាកសំណល់បណ្តាលមកពីការចោលឧបករណ៍នេសាទជុំវិញបឹងទន្លេសាប

14. សិក្សាស្រាវជ្រាវពីស្ថានភាពផលិតកម្មកសិកម្ម និងការប្រើប្រាស់ជីកសិកម្ម/ថ្នាំសម្លាប់សត្វល្អិតក្នុងវិស័យកសិកម្ម របស់ប្រជាកសិករក្នុងតំបន់បឹងទន្លេសាប (សម្រាប់ផលិតកម្ម និងការប្រើប្រាស់ជី/ថ្នាំគីមី)
15. សិក្សាតាមដានបរិមាណផលចាប់ឡូតិ៍ដាយត្រី រាជធានីភ្នំពេញ និងខេត្តកណ្ដាល
16. បច្ចុប្បន្នភាពផលិតផលកែច្នៃនៅខេត្តទាំង 6 ជុំវិញបឹងទន្លេសាប
17. ការធ្វើអាជីវកម្មត្រី (ច្រកចេញ-ចូលត្រី) នៅខេត្តទាំង 6 ជុំវិញបឹងទន្លេសាប
18. សិក្សាស្រាវជ្រាវធ្វើបច្ចុប្បន្នភាពឧបករណ៍នេសាទ នៅបណ្ដាខេត្តទាំង 6 ជុំវិញបឹងទន្លេសាប
19. តាមដានផលនេសាទរបស់អ្នកនេសាទនៅតាមដងស្ទឹងទាំង 10 ជុំវិញបឹងទន្លេសាប
20. សិក្សាស្រាវជ្រាវពីប្រសិទ្ធភាពការគ្រប់គ្រងតំបន់អភិរក្សជលផលនៅតាមបណ្ដាខេត្ត ជុំវិញបឹងទន្លេសាប
21. ចុះសិក្សាស្រាវជ្រាវពីបម្រែបម្រួលលក្ខណៈជីវសាស្ត្រធនធានជលផល តំបន់ទន្លេសាប និងតំបន់ពាក់ព័ន្ធ
22. ចុះសិក្សាស្រាវជ្រាវពីបម្រែបម្រួលលក្ខណៈជីវសាស្ត្រធនធានជលផល និងការបម្លាស់ទីរបស់ត្រីនៅតំបន់ដងមេគង្គ-បាសាក់ និងតំបន់ពាក់ព័ន្ធ
23. ចុះសិក្សាស្រាវជ្រាវពីការប្រើប្រាស់ធនធានជលផលលើវារីវប្បកម្មក្រពើ និងត្រីរ៉ស់/ឆ្តោ នៅតំបន់បឹងទន្លេសាប និងតំបន់ពាក់ព័ន្ធ
24. ចុះសិក្សាស្រាវជ្រាវ និងវាយតម្លៃលើការប៉ះពាល់នៃគុណភាពទឹកតំបន់បឹងទន្លេសាប និងតំបន់ពាក់ព័ន្ធ
25. ចុះសិក្សាស្រាវជ្រាវពីបម្រែបម្រួលនៃបរិស្ថានទឹក និងចងក្រងបញ្ជីសារពើភ័ណ្ឌប្រភពធនធានទឹកនៅតំបន់ជុំវិញបឹងទន្លេសាប
26. ចុះសិក្សាស្រាវជ្រាវពីបម្រែបម្រួលនៃបរិស្ថានទឹក ចងក្រងបញ្ជីសារពើភ័ណ្ឌប្រភពធនធានទឹកនៅតំបន់ជុំវិញបឹងទន្លេសាប
27. សិក្សាស្រាវជ្រាវពីព្រៃលិចទឹក និងការទាញយកអនុផលព្រៃលិចទឹក នៅក្នុងតំបន់បឹងទន្លេសាប និងតំបន់ពាក់ព័ន្ធ
28. សិក្សាស្រាវជ្រាវពីស្ថានភាពសហគមន៍ ក្នុងដំណើរការគ្រប់គ្រង និងអភិវឌ្ឍន៍ធនធានធម្មជាតិ និងបរិស្ថានក្នុងតំបន់ទន្លេសាប
29. សិក្សាស្រាវជ្រាវពីការគ្រប់គ្រងនិងការដោះស្រាយវិវាទផលប្រយោជន៍ក្នុងការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយសមធម៌ និងចីរភាព
30. សិក្សាស្រាវជ្រាវពីការតាមដានប្រសិទ្ធភាពនៃការអនុវត្តច្បាប់ និងបទដ្ឋានគតិយុត្តពាក់ព័ន្ធក្នុងការគ្រប់គ្រង និងអភិវឌ្ឍន៍ ធនធានធម្មជាតិ និងបរិស្ថានតំបន់ទន្លេសាប
31. ការសិក្សាពីស្ថានភាពទូទៅនៃផ្នែកសេដ្ឋកិច្ចសង្គម និងការប្រើប្រាស់ធនធានធម្មជាតិ នៅតំបន់ស្នូល (ព្រែកទាល់)ឃុំកោះជីវាំង ស្រុកឯកភ្នំ ខេត្តបាត់ដំបង
32. សិក្សាបច្ចុប្បន្នភាពប្រជាសាស្ត្រ និងសេដ្ឋកិច្ចសង្គម នៅតាមបណ្ដាលស្ទឹងទាំង 6 ជុំវិញបឹងទន្លេសាប
33. សិក្សាស្រាវជ្រាវការទ្រទ្រង់ជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាជន ដោយអាស្រ័យផលរបរនេសាទនៅតំបន់បឹងទន្លេសាប

34. សិក្សាការផ្លាស់ប្តូរគម្របដី (Land Cover Change) និងគុណភាពដី )Soil Quality( តំបន់វាលទំនាបលិចទឹកជុំវិញបឹងទន្លេសាប

**គម្រោងសកម្មភាព** ៤.២.រៀបចំបញ្ជីសារពើភ័ណ្ឌប្រភពធនធានទឹក ស្ថិតក្នុងក្របខ័ណ្ឌផែនការគ្រប់គ្រងអាងទន្លេនៅក្នុងតំបន់ទន្លេសាប

35. ធ្វើបច្ចុប្បន្នភាពលើការអភិវឌ្ឍន៍ផ្ទៃដីកសិកម្មនៅតំបន់ ១ តំបន់ ២ និងតំបន់ ៣

**គម្រោងសកម្មភាព** ៤.៣.រៀបចំបញ្ជីសារពើភ័ណ្ឌតំបន់ដីសើមជុំវិញតំបន់ទន្លេសាប

36. បច្ចុប្បន្នភាពបញ្ជីសារពើភ័ណ្ឌតំបន់ដីសើមជុំវិញតំបន់ទន្លេសាប

**លទ្ធផលរំពឹងទុក** ៥. ការគ្រប់គ្រង និងយន្តការចែករំលែកព័ត៌មាន និងទិន្នន័យ

**គម្រោងសកម្មភាព** ៥.១.គាំទ្រ និងសហការជាមួយក្រសួងស្ថាប័នជាតិក្នុងការពង្រឹង/បង្កើតឲ្យមានបណ្តាញទំនាក់ទំនងការងារតាមដានត្រួតពិនិត្យ អំពីផលប៉ះពាល់ ទៅលើធនធានធម្មជាតិ បរិស្ថាន និងល័ក្ខខ័ណ្ឌសេដ្ឋកិច្ចសង្គមកិច្ច

37. ពង្រឹងបណ្តាញទំនាក់ទំនងការងារជាមួយក្រសួងស្ថាប័ន ក្នុងការតាមដានផលប៉ះពាល់ ទៅលើធនធានធម្មជាតិបរិស្ថាន និងល័ក្ខខ័ណ្ឌសេដ្ឋកិច្ចសង្គមកិច្ច

**គម្រោងសកម្មភាព** ៥.២.គាំទ្រ និងសហការជាមួយក្រសួងស្ថាប័នជាតិ ក្នុងការពង្រឹងនីតិវិធី/វិធីសាស្ត្រតាមដានត្រួតពិនិត្យ និងវាយតម្លៃអំពីផលប៉ះពាល់មកលើធនធានធម្មជាតិ បរិស្ថាន និងល័ក្ខខ័ណ្ឌសេដ្ឋកិច្ចសង្គមកិច្ច

38. សម្របសម្រួលជាមួយក្រសួងស្ថាប័នជាតិ រៀបចំបង្កើត និងពង្រឹងនីតិវិធី/វិធីសាស្ត្រតាមដានត្រួតពិនិត្យ និងវាយតម្លៃ

**គម្រោងសកម្មភាព** ៥.៣.បង្កើតវេទិកា (Platform) ចែករំលែក និងផ្សព្វផ្សាយការសិក្សាស្រាវជ្រាវពាក់ព័ន្ធសក្តានុពល និងផលប៉ះពាល់តំបន់ទន្លេសាប និងតំបន់ពាក់ព័ន្ធ

39. ផ្សព្វផ្សាយលទ្ធផលបឋមនៃការសិក្សាស្រាវជ្រាវអំពីកាកសំណល់រឹងភូមិបណ្តែតទឹកនៃតំបន់បឹងទន្លេសាប
40. រៀបចំសិក្ខាសាលាផ្សព្វផ្សាយពីវឌ្ឍនភាពការងារប្រចាំឆ្នាំ និងទិសដៅបន្តរបស់ អាជ្ញាធរទន្លេសាប
41. ជម្រុញ និងបង្កើនការផ្សព្វផ្សាយ ព័ត៌មាន/ទិន្នន័យតាមប្រព័ន្ធ អេឡិចត្រូនិក (គេហទំព័រ បណ្តាញសង្គម ...)និងការបោះពុម្ពផ្សាយ
42. ចែករំលែកការយល់ដឹងអំពីស្ថានភាពសេដ្ឋកិច្ចសង្គមបរិស្ថានធនធានធម្មជាតិ និងការគ្រប់គ្រងតំបន់ទន្លេសាប

**ទិសដៅការងារទី** ៣. សម្របសម្រួល កសាងផែនការ និងគ្រប់គ្រង

**លទ្ធផលរំពឹងទុក** ៦. ការគ្រប់គ្រងប្រកបដោយចីរភាព ស្របតាមបទបញ្ញត្តិពាក់ព័ន្ធនឹងក្របខ័ណ្ឌការងារគ្រប់គ្រងអាងទន្លេ

**គម្រោងសកម្មភាព** ៦.១. សម្របសម្រួល និងគាំទ្រពល់កិច្ចដំណើរការអភិវឌ្ឍប្រកបដោយចីរភាពក្នុងកិច្ចការ ការពារធនធានធម្មជាតិ និងបរិស្ថានតំបន់ជុំវិញបឹងទន្លេសាប

43. ចូលរួមផ្លាស់ប្តូរបទពិសោធន៍ និងចែករំលែកការយល់ដឹង ក្នុងកិច្ចដំណើរការការអភិវឌ្ឍ ប្រកបដោយចីរភាពក្នុងកិច្ចការពារធនធានធម្មជាតិ និងបរិស្ថាន

**គម្រោងសកម្មភាព** ៦.២.សម្របសម្រួលបណ្តាញការងារជាមួយថ្នាក់ជាតិ ថ្នាក់តំបន់ និងថ្នាក់អន្តរជាតិលើបទបញ្ញត្តិនៃការគ្រប់គ្រងធនធានទឹក និងការគ្រប់គ្រងអាងទន្លេ

44. ចងក្រងរាល់ឯកសារបច្ចេកទេស និងបទបញ្ញត្តិពាក់ព័ន្ធនឹងដំណើរការការងារនៃការគ្រប់គ្រងធនធានទឹក និងការគ្រប់គ្រងអាងទន្លេ

**លទ្ធផលរំពឹងទុក** ៧. ការយល់ដឹង និងសម្របសម្រួលបណ្តាគម្រោងក្នុងតំបន់ទន្លេសាប

**គម្រោងសកម្មភាព** ៧.១.រៀបចំយន្តការបច្ចេកទេស អំពីនីតិវិធីនៃការតាមដានត្រួតពិនិត្យ និងពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ អំពីនីតិវិធីអនុវត្តន៍គម្រោងនីមួយៗ នៅតំបន់ទន្លេសាប

45. សម្របសម្រួលជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ រៀបចំនីតិវិធី/វិធីសាស្ត្រ និងចូលរួមតាមដានត្រួតពិនិត្យ និងវាយតម្លៃគម្រោងនីមួយៗដែលបាននឹងកំពុងអនុវត្តន៍នៅក្នុងតំបន់ទន្លេសាប

46. បច្ចុប្បន្នភាពទិន្នន័យគម្រោង ថ្នាក់ក្រោមជាតិ ដែលបាននឹងកំពុងអនុវត្តន៍ តំបន់ទន្លេសាប

**គម្រោងសកម្មភាព** ៧.២.ពង្រឹងការយល់ដឹង អំពីវិធីសាស្ត្រ និងនីតិវិធីនៃការតាមដានត្រួតពិនិត្យ និងវាយតម្លៃរបស់កម្មវិធី/គម្រោង

47. វគ្គពង្រឹងសមត្ថភាពមន្ត្រីបច្ចេកទេស អំពីវិធីសាស្ត្រ និងនីតិវិធីនៃការតាមដានត្រួតពិនិត្យ និងវាយតម្លៃរបស់កម្មវិធី/គម្រោង

**លទ្ធផលរំពឹងទុក** ៨.ក្របខ័ណ្ឌនៃផែនការគ្រប់គ្រងតំបន់ទន្លេសាប ត្រូវបានរៀបចំ និងផ្សព្វផ្សាយ

**គម្រោងសកម្មភាព** ៨.១.របាយការណ៍/សេចក្តីអត្ថាធិប្បាយបច្ចេកទេសពីស្ថានភាពតំបន់ទន្លេសាប (State of Tonle Sap Lake) រួមមាន សេដ្ឋកិច្ចសង្គម ធនធានធម្មជាតិ និងបរិស្ថាន

48. ចងក្រងកម្រងរបាយការណ៍បច្ចេកទេសសិក្សាស្រាវជ្រាវ សេដ្ឋកិច្ចសង្គម បរិស្ថាន ធានធានធម្មជាតិ និងការគ្រប់គ្រងតំបន់បឹងទន្លេសាប

49. រៀបចំរបាយការណ៍បច្ចេកទេសស្តីពី ស្ថានភាពសេដ្ឋកិច្ចសង្គម បរិស្ថាន ធនធានធម្មជាតិ និងការគ្រប់គ្រងបឹងទន្លេសាប

**គម្រោងសកម្មភាព** ៨.២.រៀបចំសេចក្តីព្រាងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍/គ្រប់គ្រងតំបន់ទន្លេសាប

50. រៀបចំយន្តការការងារ និងវិធីសាស្ត្ររៀបចំផែនការយុទ្ធសាស្ត្រ

51. ប្រមូលចងក្រង និងវិភាគរាល់ឯកសារ និងស្ថានភាពពាក់ព័ន្ធ

**ទិសដៅការងារទី** ៤. ការទំនាក់ទំនង និងការកសាងសមត្ថភាពភាគីពាក់ព័ន្ធ

**លទ្ធផលរំពឹងទុក** ៩.មុខងារសំខាន់របស់បឹងទន្លេសាប ត្រូវបានយល់ដឹងជាសាធារណៈ តាមរយៈការទំនាក់ទំនង និងការផ្សព្វផ្សាយព័ត៌មាន

**គម្រោងសកម្មភាព** ៩.១ រៀបចំកសាង និងអនុវត្តន៍ផែនការទំនាក់ទំនង/សម្របសម្រួល ដែលយកចិត្តទុកដាក់ទាំងលក្ខណៈបច្ចេកទេស និងឧបករណ៍ក្នុងការបង្កើនការយល់ដឹង ឲ្យបានទូលំទូលាយ

ដូចជា ៖ ឯកសារផ្នែករឹង និងទុន ការកំណត់ដៃគូ និងបណ្តាញការងារសម្រាប់ពង្រីកការផ្សព្វផ្សាយ

52. រៀបចំកសាងផែនការប្រាស្រ័យទាក់ទង Communication planning

53. អនុវត្តន៍ផែនការប្រាស្រ័យទាក់ទង (Communication Plan)

**លទ្ធផលរំពឹងទុក** ១០. សមត្ថភាពភាគីពាក់ព័ន្ធក្នុងការចែករំលែក និងសហការក្នុងការអភិវឌ្ឍការគ្រប់គ្រងធនធានធម្មជាតិ បរិស្ថាន ជីវៈចម្រុះ ប្រព័ន្ធអេកូឡូស៊ី និងល័ក្ខខ័ណ្ឌសេដ្ឋកិច្ចសង្គមកិច្ចនៃតំបន់បឹងទន្លេសាប

**គម្រោងសកម្មភាព** ១០.១.ពង្រឹងការអនុវត្តផែនការនៃការចូលរួមរបស់អ្នកពាក់ព័ន្ធ និងលើកកម្ពស់កសាងសមត្ថភាព

54. បង្កើនការលើកទឹកចិត្ត និងពង្រឹងការយល់ដឹង ដល់ការចូលរួមរបស់អ្នកពាក់ព័ន្ធ

**គម្រោងសកម្មភាព** ១០.២.កំណត់ បង្កើតភាពជាដៃគូ និងបណ្តាញការងារជាមួយក្រុមអ្នកពាក់ព័ន្ធតំបន់ទន្លេសាប (ក្រុមអ្នកប្រើប្រាស់, អង្គការមិនមែនរដ្ឋាភិបាល, កសិករ, សហគមន៍...)

55. ទស្សនៈកិច្ចសិក្សាដើម្បីផ្លាស់ប្តូរចំណេះដឹង និងចែករំលែកបទពិសោធន៍ ការគ្រប់គ្រងតំបន់ទន្លេសាប

**ទិសដៅការងារទី** ៥. ការប្រតិបត្តិរបស់អាជ្ញាធរទន្លេសាប ប្រកបដោយប្រសិទ្ធភាព និងនិរន្តរភាព

**លទ្ធផលរំពឹងទុក** ១១. ប្រសិទ្ធភាពនៃការអនុវត្តផែនការយុទ្ធសាស្ត្រ

**គម្រោងសកម្មភាព** ១១.១. តាមដានត្រួតពិនិត្យ និងវាយតម្លៃរាល់ក្របខ័ណ្ឌ និងរាល់សកម្មភាពការងារ ដែលអនុវត្តន៍ជាប្រចាំរួមជាមួយនឹងត្រួតពិនិត្យឡើងវិញពាក់កណ្តាលអាណត្តិឆ្នាំ២០១៩

56. តាមដានត្រួតពិនិត្យ និងវាយតម្លៃ វឌ្ឍនភាព នៃការអនុវត្ត ផែនការយុទ្ធសាស្ត្រ 2016-2020

57. រៀបចំផែនការសកម្មភាព 2019 របស់អាជ្ញាធរទន្លេសាប

58. ត្រួតពិនិត្យតាមដាន និងវាយតម្លៃ ផែនការសកម្មភាព 2018

**លទ្ធផលរំពឹងទុក** ១២.ធនធានហិរញ្ញវត្ថុ និងដៃគូគាំទ្រដល់បេសកកម្មការងាររបស់អាជ្ញាធរ ទន្លេសាប

**គម្រោងសកម្មភាព** ១២.១.ពង្រឹង និងពង្រីកបណ្តាញទំនាក់ទំនងការងារជាមួយក្រុមប្រឹក្សាយោបល់នៃម្ចាស់ជំនួយ (Donor Consultative Group) ក្នុងការគាំទ្រ ទាំងផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុ

59. ពង្រឹងទំនាក់ទំនងបណ្តាញការងារទំនាក់ទំនងជាមួយដៃគូអភិវឌ្ឍន៍ និងម្ចាស់ជំនួយ

**គម្រោងសកម្មភាព** ១២.២.សម្របសម្រួលក្នុងតួនាទីបណ្តាញការងារអង្គការអាងទន្លេ

60. ពង្រឹងបណ្តាញទំនាក់ទំនងការងារ ជាមួយនឹងអង្គការអាងទន្លេ ថ្នាក់តំបន់ និងអន្តរជាតិ

**គម្រោងសកម្មភាព** ១២.៣.សមាហរណកម្មប្រភពថវិកា/មូលនិធិខាងក្នុងរបស់អាជ្ញាធរទន្លេសាប (ថវិការដ្ឋ, ម្ចាស់ជំនួយ, គម្រោងនានា...)

61. រៀបចំគម្រោងវិនិយោគសាធារណៈ PIP 2019-2021 សម្រាប់ អាជ្ញាធរទន្លេសាប

62. ពង្រឹងប្រសិទ្ធភាពការកសាងផែនការ ថវិកាកម្មវិធីប្រចាំឆ្នាំរបស់ អ.ទ.ស

63. សមាហរណកម្មប្រភពថវិកា/មូលនិធិ (ថវិការដ្ឋ, ម្ចាស់ជំនួយ, គម្រោងនានា...) ក្នុងផែនការថវិការបស់អាជ្ញាធរទន្លេសាប

**លទ្ធផលរំពឹងទុក** ១៣.ធនធានមនុស្ស និងនីតិវិធីរដ្ឋបាល ដើម្បីគាំទ្រដល់ការអនុវត្តសកម្មភាពរបស់អាជ្ញាធរទន្លេសាប

**គម្រោងសកម្មភាព** ១៣.១. ជួសជុលថែទាំ មធ្យោបាយ សម្ភារបរិក្ខា អគារ និងប្រេងឥន្ធនៈ

64. ផ្គត់ផ្គង់សម្ភារបរិក្ខា ប្រេងឥន្ធនៈ និងមធ្យោបាយសម្រាប់ប្រតិបត្តិការការងាររបស់ អ.ទ.ស
65. ជួសជុលថែទាំ មធ្យោបាយ សម្ភារបរិក្ខា និងអគារសម្រាប់អាជ្ញាធរទន្លេសាប

**គម្រោងសកម្មភាព** ១៣.២.នីតិវិធី បទបញ្ជាផ្ទៃក្នុង សម្រាប់ដំណើរការការងារប្រចាំ

66. ពង្រឹងប្រសិទ្ធភាពការងារគ្រប់គ្រងរដ្ឋបាល បុគ្គលិក មន្ត្រីរាជការក្នុងដំណើរការការងារប្រចាំថ្ងៃរបស់អាជ្ញាធរទន្លេសាប
67. បង្កើនការយកចិត្តទុកដាក់ និងលើកទឹកចិត្តជូនមន្ត្រីរាជការបម្រើការងារនៅ អាជ្ញាធរទន្លេសាប

**គម្រោងសកម្មភាព** ១៣.៣. ជ្រើសរើសមន្ត្រីប្រកបដោយសមត្ថភាពតាមការចាំបាច់

68. ជ្រើសរើសមន្ត្រីតាមតួនាទីចាំបាច់
69. ជ្រើសរើស និងបញ្ចូលមន្ត្រីជាប់សន្យា

**គម្រោងសកម្មភាព** ១៣.៤.កសាងសមត្ថភាពមន្ត្រីអាជ្ញាធរទន្លេសាប និងមន្ត្រីក្រសួងស្ថាប័នពាក់ព័ន្ធ

70. វគ្គបណ្តុះបណ្តាលពីវិធីសាស្ត្រសិក្សាស្រាវជ្រាវ ការវិភាគទិន្នន័យ និងការសរសេរបកស្រាយ
71. វគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាព ពីការគ្រប់គ្រងព័ត៌មានវិទ្យា ( Information Technology Management )
72. វគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាព ពីការគ្រប់គ្រងដីសើម និងទីជម្រាល( Wetland and Watershed Management )
73. វគ្គបណ្តុះបណ្តាល ពីវិធីសាស្ត្រការគ្រប់គ្រង និងវិភាគវាយតម្លៃបរិមាណផលចាប់ធនធានជលផល ( ១.ប្រចាំថ្ងៃរបស់អ្នកនេសាទតាមដងស្ទឹង បឹង និង ២.តាមឡូត៍ជាយ )
74. វគ្គបណ្តុះបណ្តាល ពីបម្រែបម្រួលស្ថានភាពរបបជលសាស្ត្រ-ឧតុនិយម និងតម្រូវការទឹកស្រោចស្រព
75. វគ្គបណ្តុះបណ្តាល ពីវិធីសាស្ត្រនៃការសរសេររបាយការណ៍បច្ចេកទេស( Technical report writing )

# ម៉ាទ្រិចផែនការសកម្មភាព ឆ្នាំ ២០១៨ របស់ អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប

| ទិសដៅ/លទ្ធផលរំពឹងទុក | គម្រោង/សកម្មភាព | | ពេលវេលាអនុវត្តន៍ ២០១៨ ( ខែ ) | | | | | | | | | | | | មន្ត្រី/បុគ្គលិកទទួលខុសត្រូវ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | |
| ទិសដៅទី ១. ពង្រឹងគោលនយោបាយ បទបញ្ញត្តិ និងស្ថាប័ន | | | | | | | | | | | | | | | |
| ១. គោលនយោបាយសម្រាប់ការណែនាំអភិបាលកិច្ចទឹក និងសកម្មភាពការងារអាជ្ញាធរទន្លេសាប | ១.១.លើកកម្ពស់គោលនយោបាយគ្រប់គ្រងធនធានទឹកឲ្យបានទូលំទូលាយនៅប្រទេសកម្ពុជារួមទាំងនៅថ្នាក់តំបន់ ថ្នាក់ជាតិ និងនៅតំបន់ទន្លេសាប | | | | | | | | | | | | | | |
| | 1 | ផ្សព្វផ្សាយ និងបង្កើនការយល់ដឹងគោលនយោបាយគ្រប់គ្រងធនធានទឹកឲ្យបានទូលំទូលាយ ដល់មន្ត្រី អ.ទ.ស | | | | | | | | | | | | | នាយកដ្ឋាននីតិកម្ម និងផ្សព្វផ្សាយ (លោក លឹម ហេង និងការិ.នីតិកម្ម និងការិ.ផ្សព្វផ្សាយ) |
| | 1.1 | រៀបចំឯកសារពាក់ព័ន្ធដោយពិគ្រោះយោបល់ជាមួយក្រសួងធនធានទឹក | √ | | | | | | | | | | | | |
| | 1.2 | លើកសំណើដើម្បីដំណើរការអនុវត្តគម្រោងសកម្មភាព | | √ | | | | | | | | | | | |
| | 1.3 | ផ្សព្វផ្សាយ និងបង្កើនការយល់ដឹង | | | √ | | | | | | | | | | |
| | 1.4 | របាយការណ៍ការផ្សព្វផ្សាយការយល់ដឹង | | | √ | | | | | | | | | | |
| | 1.5 | របាយការណ៍តាមដានការអនុវត្តសកម្មភាពត្រីមាស-ឆមាស-ប្រចាំឆ្នាំ | | | √ | | | | | | | | | | |
| | ១.២.សម្របសម្រួលបញ្ជ្រាបផែនការយុទ្ធសាស្ត្រគ្រប់គ្រងតំបន់ទន្លេសាប ក្នុងគោលនយោបាយយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ | | | | | | | | | | | | | | |
| | 2 | កំណត់រាល់សូចនាករជាធាតុចូលសំខាន់ៗក្នុងផែនការយុទ្ធសាស្ត្រគ្រប់គ្រងតំបន់ទន្លេសាប | | | | | | | | | | | | | អគ្គលេខាធិការដ្ឋាន |

| | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | 2.1 | ពិនិត្យ និងចងក្រងខ្លឹមសារសូចនាករសំខាន់ៗដែលនឹងត្រូវរៀបចំផែនការយុទ្ធសាស្ត្រគ្រប់គ្រងតំបន់ទន្លេសាប | √ | √ | √ | | | | | | | | | | |
| | 2.2 | ទំនាក់ទំនង និងប្រឹក្សាយោបល់ជាមួយក្រសួងធនធានទឹក និងឧតុនិយមក្នុងខ្លឹមសារយុទ្ធសាស្ត្រគោលនយោបាយរបស់ក្រសួងក៏ដូចជារាជរដ្ឋាភិបាល | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | |
| | 2.3 | ទំនាក់ទំនងប្រឹក្សាជាមួយក្រសួងធនធានទឹក ឧត្តមក្រុមប្រឹក្សាអភិវឌ្ឍន៍ជាតិ និងក្រសួងផែនការ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | |
| | 2.4 | របាយការណ៍ (តាមការចាំបាច់) | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | |
| | 2.5 | របាយការណ៍តាមដានការអនុវត្តសកម្មភាពត្រីមាស-ឆមាស-ប្រចាំឆ្នាំ | | | √ | | | √ | | | √ | | | √ | |
| | ១.៣.សម្របសម្រួលជាមួយក្រសួង ស្ថាប័ន និងភាគីពាក់ព័ន្ធ ដើម្បីដាក់បញ្ចូលគោលការណ៍ការគ្រប់គ្រងធនធានទឹកចម្រុះ ក្នុងបទបញ្ញត្តិ/ផែនការតាមវិស័យ និងជំរុញឲ្យមានសុខដុមនីយកម្មតាមការចាំបាច់ | | | | | | | | | | | | | | |
| | 3 | កំណត់ពីសូចនាករ និងទស្សនទានដែលជាធាតុចូលសំខាន់នៃគោលការណ៍គ្រប់គ្រងធានធានទឹកចម្រុះសម្រាប់ការអភិវឌ្ឍន៍និងអភិរក្សតំបន់ទន្លេសាបប្រកបដោយចីរភាព | | | | | | | | | | | | | |
| | 3.1 | សម្របសម្រួលប្រឹក្សាយោបល់ជាមួយក្រសួងស្ថាប័ន និងភាគីពាក់ព័ន្ធដើម្បីចូលរួមនិងលើកកម្ពស់ការអនុវត្តគោលការណ៍គ្រប់គ្រងធនធានទឹកចម្រុះ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | អគ្គលេខាធិការដ្ឋាន |
| | 3.2 | របាយការណ៍ (តាមការចាំបាច់) | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | |
| | 3.3 | របាយការណ៍តាមដានការអនុវត្តសកម្មភាពត្រីមាស-ឆមាស-ប្រចាំឆ្នាំ | | | √ | | | √ | | | √ | | | √ | |

| | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ២. បទបញ្ញត្តិអភិបាលកិច្ចទឹកត្រូវបានបង្កើតឡើងនៅតំបន់ទន្លេសាប | ២.១.សម្របសម្រួល និងប្រតិបត្តិតាមរាល់បទបញ្ញត្តិពាក់ព័ន្ធនឹងច្បាប់ធនធានទឹក និងក្របខ័ណ្ឌក្នុងការគ្រប់គ្រងអាងទន្លេរបស់ព្រះរាជាណាចក្រកម្ពុជា | | | | | | | | | | | | | | |
| | 4 | ផ្សព្វផ្សាយ និងបង្កើនការយល់ដឹងពីបទបញ្ញត្តិពាក់ព័ន្ធនឹងច្បាប់គ្រប់គ្រងធនធានទឹក | | | | | | | | | | | | | នាយកដ្ឋាននីតិកម្ម និងផ្សព្វផ្សាយ (លោក លឹម ហេង និង ការិ.នីតិកម្ម និង ការិ.ផ្សព្វផ្សាយ) |
| | 4.1 | រៀបចំឯកសារពាក់ព័ន្ធដោយពិគ្រោះយោបល់ជាមួយក្រសួងធនធានទឹក | √ | | | | | | | | | | | | |
